# 「សេចក្តីជូនដំណឹងអំពីរបៀបធ្វើការចុះឈ្មោះកក់ទុកជាមុនតាមរយៈប្រព័ន្ធអនឡាញ សម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩」

◈ ប្រពន្ធ័ចុះឈ្មោះកក់ទុកជាមុនតាមរយៈប្រព័ន្ធអនឡាញសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩។ អាចចុះឈ្មោះកក់ទុកជាមុនបានតាមរយៈគេហទំព័រ (ncvr.kdca.go.kr) (អាចចុះឈ្មោះបានតាមរយៈអេបទូរស័ព្ទផងដែរ) អាចចុះឈ្មោះកក់ទុកជាមុនបានតាមរយៈប្រព័ន្ធអនឡាញចំនួន2ជំហាន។

□របៀបធ្វើការចុះឈ្មោះកក់ទុកជាមុនតាមរយៈប្រព័ន្ធអនឡាញសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩។

| ការពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួន | ⇨ | ការបញ្ចូលព័ត៌មានផ្ទាល់ខ្លួន | ⇨ | ពិនិត្យមើលព័ត៌មាននៃការចុះឈ្មោះកក់ទុកជាមុន | ⇨ | ការបញ្ចូលឯកសារព័ត៌មានអំពីការចុះឈ្មោះកក់ទុកជាមុន |
|---|---|---|---|---|---|---|
| ត្រូវពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួនដោយជ្រើសរើសក្នុងចំណោម 5 របៀប។ | | ដំណើរការចុះឈ្មោះកក់ទុកជាមុនជាមួយមន្ទីរពេទ្យ និង ពិនិត្យឈ្មោះបេក្ខជន។ | | ពិនិត្យមើលព័ត៌មាននៃការចុះឈ្មោះកក់ទុកជាមុនដែលបានបញ្ចូលទៅ។ | | អាចលុបចោល និងពិនិត្យមើលព័ត៌មានអំពីការចុះឈ្មោះកក់ទុកជាមុនបានតាមរយៈគេហទំព័រ។ |

## ○ ជំហានទី1 (ការបញ្ចូលព័ត៌មានអំពីការចុះឈ្មោះកក់ទុកជាមុន)





### ① ត្រូវពិនិត្យមើលព័ត៌មានអំពីការចុះឈ្មោះកក់ទុកជាមុន

- សាមីខ្លួនត្រូវជ្រើសរើសការផ្ទៀងផ្ទាត់ព័ត៌មានមួយអោយបានត្រឹមត្រូវក្នុងចំណោម5របៀបដោយខ្លួនឯង។
- អាចពិនិត្យមើលអោយបានត្រឹមត្រូវដែលបានផ្តល់តាមរយៈ NAVER, KAKAO TALK, PASS, ឯកសាធារណៈ, ទូរស័ព្ទដៃ

※ ឯកសាសាធារណៈ: តម្រូវអោយពិនិត្យមើលកាលបរិច្ឆេទផុតកំណត់អោយច្បាស់លាស់។

### ② បន្ទាប់ពីសាមីខ្លួនពិនិត្យមើលព័ត៌មានត្រឹមត្រូវហើយ ត្រូវបញ្ចូល ព័ត៌មានផ្ទាល់ខ្លួន

- បន្ទាប់ពីសាមីខ្លួនពិនិត្យមើលព័ត៌មានត្រឹមត្រូវហើយ សូមបំពេញឈ្មោះ, បន្ទាប់ពីបញ្ចូលលេខទូរស័ព្ទ, លេខអត្តសញ្ញាណប័ណ្ណ (លេខសម្គាល់ខ្លួនជនបរទេស) ហើយ សូមចុចប៊ូតុង ‘ពិនិត្យឈ្មោះបេក្ខជន’។

- បន្ទាប់ពីពិនិត្យឈ្មោះបេក្ខជនហើយ <u>សូមជ្រើសរើសពេលវេលាការចុះឈ្មោះកក់ទុកជាមុនជាមួយខាងមន្ទីរពេទ្យហើយ</u> ចុចប៊ូតុង 'ការចុះឈ្មោះកក់ទុកជាមុន'ដើម្បីដំណើរការចុះឈ្មោះកក់ទុកជាមុនបាន។

**○ ជំហានទី2 (សេចក្តីណែនាំអំពីការបញ្ចប់ការចុះឈ្មោះកក់ទុកជាមុន)**





**① ផ្ទាំងអេក្រង់ណែនាំអំពីការបញ្ចប់ការចុះឈ្មោះកក់ទុកជាមុន**

- ជំហានទី2 (ការណែនាំអំពីការបញ្ចប់ការចុះឈ្មោះកក់ទុកជាមុន) អាចពិនិត្យមើលព័ត៌មានការចុះឈ្មោះកក់ទុកជាមុន ដែលបានបំពេញរួចរាល់នៅក្នុងដំណាក់កាលទី1 នៅលើអេក្រង់ទូរស័ព្ទ។

**② ផ្ញើរព័ត៌មានការចុះឈ្មោះកក់ទុកជាមុនតាមរយៈទូរស័ព្ទដៃ**

- បន្ទាប់ពីបានបញ្ចប់ការចុះឈ្មោះកក់ទុកជាមុនសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ហើយ សូមផ្ញើរព័ត៌មានការចុះឈ្មោះកក់ទុកជាមុនតាមរយៈទូរស័ព្ទដៃ។ អាចលុបចោល និង ការពិនិត្យព័ត៌មានការចុះ ឈ្មោះកក់ទុកជាមុនតាមតាមរយៈទិន្នន័យដែលបានបញ្ជូនទៅ ដូចជា (លេខចុះឈ្មោះកក់ទុកជាមុន លេខអត្តសញ្ញាណប័ណ្ណ លេខសម្គាល់ខ្លួនជនបរទេស និង ឈ្មោះបេក្ខជន) ។ ព័ត៌មានដែលអាចអោយ សាមីខ្លួនពិនិត្យមើលនៅក្នុងបញ្ជីចុះឈ្មោះ 'ការលុបចោល និងការចុះឈ្មោះកក់ទុកជាមុន' នៅក្នុងគេហទំព័រ។

**※ ក្នុងករណីជនបរទេស អាចដំណើរការចុះឈ្មោះកក់ទុកជាមុនបាន '១០លេខ' ដោយលេខបញ្ចប់ ថ្ងៃខែឆ្នាំកំណើត លេខសម្គាល់ខ្លួនជនបរទេស។**

**※ ជនបរទេសដែលគ្មានធានារ៉ាប់រងសុខភាព សូមជួយចុះឈ្មោះកក់ទុកជាមុននៅ 'មជ្ឈមណ្ឌលចាក់ថ្នាំបង្ការ' ដែលនៅជិតបំផុត។**

**※ សូមទៅចាក់វ៉ាក់សាំងកុំអោយយឺតនៅមជ្ឈមណ្ឌលចាក់វ៉ាក់សាំងដែលបានជ្រើសរើសអោយទាន់ពេលវេលា។**

**※ បើមានសំណួរទាក់ទងនឹងចាក់វ៉ាក់សាំងការពារជំងឺកូវីដ 19 សូមទំនាក់ទំនងទៅកាន់ទូរស័ព្ទលេខ ☎1339 នៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ 19 ដោយរដ្ឋាភិបាលក្នុងតំបន់។**

* មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ 19 ដោយរដ្ឋាភិបាលក្នុងតំបន់:

【ការពិគ្រោះយោបល់មានជាភាសាកូរ៉េ】 សូមទំនាក់ទំនង 'ភ្ជាប់ទៅគេហទំព័រ ncvr.kdca.go.kr >ចូលទៅកាន់ការចុះឈ្មោះកក់ទុកជាមុន> កន្លែងជូនដំណឹង> មជ្ឈមណ្ឌលផ្តល់ព័ត៌មាន'